Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

PayPal https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php

HONEYCOMB 2/1 (January 2001): 129–132



# Meet Yos Em Sithan

*Debbi MAHER*



*YOS Em Sithan*

Yos Em Sithan became a Christian in 1975, one week before the Khmer Rouge invaded Phnom Penh. Her brother Yos Ann Tipo led her to the Lord; her sister Yos Kam Molly was already a strong believer.

Having so little time to understand her new faith, she cried almost daily to God, "Why was this all happening? Please help me." Such was the extent of her new faith. God answered her prayers in a variety of ways. Although she had previously been a student and her father a government official, she was able to convince the Khmer Rouge soldiers otherwise and thereby avoid almost certain elimination. She was often asked what she used to do. "Are you a student? What was your job before?" She replied that she had been a vegetable seller in the market.

She was fortunate that her entire family was able to remain together when they were relocated to Prey Veng to work as rice farmers. Suspicious that she and her family were from the educated class, the soldiers would often ask questions regarding their skill in farming or hard labor. God intervened by giving her rice-planting skills, which as a city girl she had never had. Another means by which God provided for their family was Em Sitan's father's background with the Ministry of Agriculture. This gave him some understanding of farming, and allowed them to secretly grow extra food for their family. In 1978 her family was eventually separated, and the Khmer Rouge arranged for her subsequent marriage.

After the fall of the Pol Pot regime, her family did not immediately declare their faith openly. Her father, knowing the then-current system of government, felt strongly that they should be cautious. He had witnessed the deportation of a World Council of Churches representative known for his evangelistic activity.

1989 was a year of new life, and the realization of eternal life, in Em Sithan's family. Her husband, Malk Wathna, become a Christian following study in Cuba, and her father, Yos Ann, went home to be with the Lord. He had been respected in both Christian and Buddhist circles. The arrangements for his funeral created a major dilemma. How would they perform the ceremony in a manner that reflected their Christian faith? They sought permission from the local authorities, only to be turned down. They did have a ceremony with many in attendance. Seang Ang performed the ceremony, and leaders such as Oung Rien and Sar Paulerk were present. After this Em Sithan began to wonder just how we as Christians should practice our faith? She was encouraged by a leader in the Catholic community to write the government for permission to actively express their faith.

She knew of a prominent official—related to her father by marriage—who had close ties with high-ranking government members. Because she and her family were not associated with any certain group, and because of the tremendous respect her father had in government circles, he agreed to help her submit a letter to the proper authorities. She then began to feel that "God had a plan for us." She met regularly with an official responsible for religious matters to discuss Christianity. He wanted to know what Christians

were and who was behind them (meaning outside foreign support). When he realized that she had no outside support and that she was a teacher in the Ministry of Education, he saw that it was possible to be a Christian and simultaneously maintain love for Cambodian people and culture. Permission was granted for Cambodian Christians to openly express their faith.

In 1990 the Olympic Church opened its doors. In the beginning, Em Sithan's family would simply read the Bible, sing songs, and listen to FEBC (Far East Broadcasting Cambodia). They started without any denominational or outside support in order to avoid being perceived as having been deceptive in their initial discussions with the government. Today the church has between forty and fifty members. It has no pastor. She calls herself a church leader. There are four elders who share the speaking duties each week. Bible study is taken seriously in this church. Em Sithan has a TEE degree, and the church has an active outreach program. The Olympic Church has sister churches in Kampong Cham, Kang Meas, Batheay, and Rokakong (Kandal Province).

From 1993–97 Em Sithan served on the translation committee with Arun Sok Nep for the new translation of the Cambodian Bible. Until March 2000 she had maintained a part-time position within the Ministry of Education. She now works full time for the Bible Society as their Executive Secretary. The mission of the Bible Society is the translation, printing, and distribution of the Word of God for everyone, everywhere in Cambodia—especially the non-Christian.

Em Sithan remains optimistic regarding the growth of Christianity here. She sees the church and growing both spiritually and materially. She would caution fellow believers to always remain faithful to Jesus, as He is their only Savior. Following Christianity for power and gain is wrong. She is saddened to see poor Cambodians giving offerings to build lavish pagodas, which seldom address their personal or spiritual needs. She feels strongly that tithes, which go into churches, should be used outside the church for God's work. The Olympic Church uses their offerings for outreach and missions in the provinces. She would also enjoy having more fellowship with other local Christians, but finds that

her days are full with the demands of her church and the Bible Society.

When discussing the evangelization of Cambodia, Em Sithan has an open mind, and welcomes foreign missionaries. She believes strategies should fit the situation as well as the country. Evangelism must be lived as well as spoken. It is important to share the need to love God and each other. What should not be done is to spend too much time arguing over denominations and translations. What is important is to obey God, fear and respect Him. He, alone is the judge; we should not judge each other.

In 1994, American evangelist Mike Evans brought a disastrous "crusade" to Cambodia. He made promises of healing to all who came, and eventually narrowly avoided having the stage overturned by the riotous stadium crowd. When Em Sithan saw the promotion of this event, she found it disconcerting that the evangelist's name was given more prominence than name of Jesus Christ. She made the decision that Olympic Church would not take part in this event. When co-workers at the Ministry of Education taunted her regarding the failed spectacle, she simply replied, "If you have questions regarding my Christianity, I would be happy to share with you. If, on the other hand, you wish to argue and criticize the events of the crusade, then I really have nothing to say." She believes as Christians study the word of God they will gain discernment regarding the various messages and messengers who come to Cambodia.

Em Sithan admits that there are many misconceptions regarding Cambodian Christians. A former co-worker at the Ministry of Education was surprised that she was a Christian; after all, she was an educated woman. She continued with the equally popular question, "So how much money do you receive for having a church in your home?" She replied, "If you really believe my faith is just about the money, why don't you open up your house and make some money as I do?"

Em Sithan was right to believe that God has a plan for her and Cambodia. He has shown her His faithfulness, protection, perfect timing, and provision. She has responded with a sincere desire to serve Him with humility, integrity, and a love for her country and its people.

សំណុំទិកឃ្មុំ ២/១ (មករា ២០០១)៖ ១៣៣-១៤០



# ការជួបជាមួយអ្នកស្រី យស់ ឯមស៊ីថាន

លោកស្រី ដេមី ម៉ាហ៊ើ



លោកស្រី យស់ ឯមស៊ីថាន

លោកស្រី យស់ ឯមស៊ីថាន ថ្វាយជីវិតដល់ព្រះគ្រីស្ទ នៅក្នុងឆ្នាំ ១៩៧៥ គឺនៅពេលមួយអាទិត្យមុនពួកខ្មែរក្រហមចូលលុកលុយ ក្នុងទីក្រុងភ្នំពេញ ។ ប្អូនប្រុសរបស់គាត់ឈ្មោះ យស់ អានទីប៉ូ បាននាំគាត់ និង ប្អូនស្រីរបស់គាត់ឈ្មោះ យស់ កាំម៉ូលី ឲ្យថ្វាយជីវិតទទួលជឿព្រះអម្ចាស់ ហើយប្អូនស្រីគាត់ក៏ជាអ្នកជឿរឹងមាំ កាលពីពេលនោះដែរ ។

ដោយសារតែមានពេលតិចតួច ដើម្បីឲ្យបានយល់ច្បាស់ចំពោះជំនឿថ្មីរបស់គាត់នោះ គាត់បានយំស្ទើររាល់ថ្ងៃ ហើយបានទូលសួរព្រះជាម្ចាស់ថា៖ "ហេតុអ្វីបានជារឿងរ៉ាវទាំងនេះកើតឡើងដូច្នេះ?" គាត់ក៏បានទូលដល់ព្រះជាម្ចាស់ផងដែរថា "ព្រះអម្ចាស់អើយ សូមជួយកូនផង" ។ ការបែបនោះបានធ្វើឲ្យជំនឿថ្មីរបស់គាត់រីកចំរើនឡើង ។ ព្រះជាម្ចាស់បានឆ្លើយតបចំពោះការអធិស្ឋានទាំងនោះតាមបែបផ្សេងៗ ។ ទោះបីមុនពេលខ្មែរក្រហមចូលមកគាត់ជានិស្សិត និងឪពុករបស់គាត់ជាមន្ត្រីធ្វើការនៅក្នុងរដ្ឋាភិបាលក៏ដោយ គាត់អាចបង្ហាញឲ្យពួកទាហានខ្មែរក្រហម ទុកចិត្តបើពុំនោះទេខ្មែរក្រហមមិនទុកឲ្យរស់ឡើយ ។ ខ្មែរក្រហមតែងតែសួរគាត់ពីមុខរបរពីមុនរបស់គាត់ ។"តើអ្នកឯងជានិស្សិតឬ?" "ធ្វើការអីពីមុន?" ចម្លើយរបស់គាត់នោះគឺថា គាត់ជាអ្នកលក់បន្លែនៅឯផ្សារ ។

គាត់មានសំណាង ដោយបានខ្មែរក្រហមជំលៀសទៅធ្វើស្រែនៅខេត្តព្រៃវែង ទៅទាំងគ្រួសារតែម្តង ។ ដោយមានការសង្ស័យថា គាត់និង គ្រួសាររបស់គាត់ជាត្រកូល ដែលបានទទួលការអប់រំចេះដឹងនៅក្នុងសង្គម ពួកទាហានខ្មែរក្រហមតែងតែព្យាយាមសួរនូវសំណួរជាច្រើនដើម្បីល្បងល មើលការប៉ិនប្រសប់ផ្នែករបរធ្វើស្រែចំការ ឬ ក៏ដាក់ការងារលំបាកៗឲ្យធ្វើ ។ ព្រះជាម្ចាស់ជួយក្នុងការនោះ ដោយផ្តល់ឲ្យគាត់នូវភាពស្ទាត់ជំនាញផ្នែកស្ទូងស្រូវ ដែលអ្នកទីក្រុងមិនដែលធ្លាប់ចេះពីមុនមក ។ មធ្យោបាយមួយទៀត ដែលព្រះជាម្ចាស់ការពារនោះ គឺដោយផ្តល់ឲ្យឪពុករបស់លោកស្រី ឯម ស៊ីថាន ធ្លាប់ជាមន្ត្រីរដ្ឋការធ្វើការនៅក្រសួងកសិកម្ម ។ ការនេះឯង ដែលអាចឲ្យគាត់អាចយល់ដឹងពីរបៀបធ្វើស្រែចំការខ្លះៗ និង អាចលបដាំដំណាំខ្លះ ដើម្បីជួយផ្តល់អាហារដល់គ្រួសាររបស់គាត់បន្ថែមទៀត ។ នៅក្នុងឆ្នាំ ១៩៧៨ គ្រួសាររបស់គាត់ត្រូវបានបែកខ្ញែកគ្នា ហើយនិងពេលនោះខ្មែរក្រហមបានរៀបចំឲ្យគាត់រៀបការ ។

បន្ទាប់ពីរបប ប៉ុល ពត ត្រូវរលំដួលទៅ គ្រួសាររបស់គាត់មិនទាន់ហ៊ានប្រកាសពីជំនឿរបស់ខ្លួនដោយបើកចំហឡើយ ។ ឪពុករបស់គាត់ស្គាល់ពីប្រព័ន្ធដឹកនាំរបស់រដ្ឋាភិបាលសម័យនោះ ដោយដឹងយ៉ាងច្បាស់ថា គួរតែប្រុងប្រយ័ត្ន ។ ឪពុករបស់គាត់បានឃើញដោយផ្ទាល់ភ្នែក នូវការដែលរដ្ឋាភិបាលបញ្ជូនតំណាង WCC ដែលគេស្គាល់ថាជាសកម្មជនផ្សាយដំណឹងល្អឲ្យចេញក្រៅប្រទេស ។

នៅក្នុងឆ្នាំ ១៩៨៩ គឺជាឆ្នាំនៃជីវិតថ្មី និង គឺជាឆ្នាំនៃការបានដឹងពីជីវិតអស់កល្បជានិច្ចរបស់គ្រួសារលោកស្រី ឯម ស៊ីថាន ។ ប្ដីរបស់គាត់ឈ្មោះលោក ម៉ាក់ វឌ្ឍនា បានទទួលជឿព្រះយេស៊ូ បន្ទាប់ពីបានទៅសិក្សានៅប្រទេសគុយបា ។ ឪពុករបស់លោកស្រី ឯម ស៊ីថាន ឈ្មោះលោក យស់ អាន បានទៅនៅជាមួយនឹងព្រះអម្ចាស់នៅក្នុងឆ្នាំនោះដែរ ។ ឪពុក របស់គាត់ជាមនុស្ស ដែលគេគោរពរាប់អាន ទាំងនៅក្នុងរង្វង់គ្រីស្ទបរិស័ទ ក៏ដូចគ្នានិងក្នុងរង្វង់ពុទ្ធបរិស័ទ ។ នៅក្នុងការរៀបចំធ្វើបុណ្យសពរបស់គាត់មានការពិបាកក្នុងការសម្រេចចិត្តយ៉ាងខ្លាំង ។ តើពួកគេត្រូវធ្វើពិធីតាមរបៀបណា ដើម្បីបញ្ជាក់ឲ្យគេដឹងពីជំនឿគ្រីស្ទបរិស័ទរបស់ខ្លួននោះ? ពួកគេបានសុំច្បាប់ដល់អាជ្ញាធរ តែមិនបានសម្រេចសោះ ។ ពួកគេក៏បានធ្វើពិធីមួយ ដែលមានមនុស្សចូលរួមយ៉ាងច្រើនកុះករ ។ លោកព្រឹទ្ធាចារ្យ សៀង អង បានធ្វើពិធីនោះ ហើយនិង អ្នកដឹកនាំជាច្រើនរូបទៀត ក៏បានចូលរួមដែរ ដូចជាលោក អ៊ួង រៀន និង លោក សរ ពលៈ ។ បន្ទាប់ពីពេលនោះ លោកស្រី ឯម ស៊ីថាន ចាប់ផ្ដើមឆ្ងល់ក្នុងចិត្ត ចុះថាតើយើងជាគ្រីស្ទានត្រូវធ្វើយ៉ាងម៉េចចំពោះសិទ្ធិជំនឿរបស់ខ្លួន នៅពេលនោះមានគ្រីស្ទបរិស័ទម្នាក់នៅក្នុងព្រះសហគមន៍កាតូលិកបានលើកទឹកចិត្តឲ្យគាត់សរសេរសំបុត្រសុំច្បាប់អនុញ្ញាត ពីរដ្ឋាភិបាលដោយបញ្ជាក់ពីជំនឿរបស់ខ្លួនដោយបើកចំហ ។

គាត់បានស្គាល់មន្ត្រីសំខាន់ម្នាក់ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទនឹងសមាជិកជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល ។ មន្ត្រីម្នាក់នេះត្រូវជាប់ជាសាច់ញាតិជាមួយនឹងសពឪពុករបស់គាត់ ។ ដោយសារតែគាត់ និងគ្រួសាររបស់គាត់ មិនមានជាប់ជំពាក់ជាមួយនឹងក្រុមជំនុំណាមួយច្បាស់លាស់ និង ដោយសារតែឪពុកគាត់មានការគោរពរាប់អានយ៉ាងជ្រាលជ្រៅនៅក្នុងរង្វង់ជួររដ្ឋាភិបាល មន្ត្រីម្នាក់នោះឯងក៏ព្រមជួយដាក់សំបុត្រសុំច្បាប់អនុញ្ញាតនោះទៅដល់កន្លែងអាជ្ញាធរជំនាញត្រឹមត្រូវ ។ នៅត្រង់ចំណុចនោះឯង គាត់ចាប់ផ្តើមមានអារម្មណ៍ថា "ព្រះជាម្ចាស់មានផែនការសំរាប់យើង" គាត់បានទៅជួបជាមួយនឹងមន្ត្រីម្នាក់ ដែលទទួលបន្ទុកកិច្ចការសាសនាជាញឹកញាប់ ដើម្បីសុំពិភាក្សាពីជំនឿគ្រីស្ទបរិស័ទ ។ មន្ត្រីនោះចង់ដឹងថាតើអ្វីទៅជាគ្រីស្ទបរិស័ទ ហើយតើនរណាជាអ្នកនៅពីក្រោយ (គឺមានន័យថាការគាំទ្រពីបរទេស) ។ នៅពេលដែលមន្ត្រីនោះបានដឹងថា គាត់គ្មានបានទទួលការគាំទ្រអ្វីពីខាងក្រៅនោះឡើយ ហើយបានដឹងថា គាត់ជាគ្រូបង្រៀននៅក្នុងក្រសួងអប់រំ មន្ត្រីនោះបានឃើញថាគាត់ជាគ្រីស្ទបរិស័ទ ប៉ុន្តែនៅស្រឡាញ់ជនជាតិខ្មែរ និងទំនៀមទម្លាប់ខ្មែរទើបព្រមអនុញ្ញាតច្បាប់ឲ្យគ្រីស្ទបរិស័ទខ្មែរជឿដោយស្របច្បាប់ ។

នៅក្នុងឆ្នាំ ១៩៩០ ពួកជំនុំនៅអូឡាំពីកបានបើកទ្វារប្រជុំជាផ្លូវការ ។ ពេលចាប់ផ្តើមដំបូង គ្រួសាររបស់លោកស្រី ឯម ស៊ីថាន គ្រាន់តែអានព្រះគម្ពីរ ច្រៀងសរសើរដំកើងព្រះ និងស្តាប់វិទ្យុសម្លេងនៃសេចក្តីស្រឡាញ់ (FEBC) ។ ពួកជំនុំនេះចាប់ផ្តើមឡើង ដោយគ្មាននិកាយ ឬការឧបត្ថម្ភគាំទ្រណាពីខាងក្រៅឡើយ ដើម្បីជៀសវាងការ ដែលគេមើលឃើញថា មានការឆបោក ឬ មិនស្មោះត្រង់ ផ្ទុយពីការដែលបានពិភាក្សាដំបូងជាមួយរដ្ឋាភិបាលនោះ ។ សព្វថ្ងៃនេះពួកជំនុំកើនឡើងរហូតដល់ ៤០-៥០ នាក់ហើយ គ្មានគ្រូគង្វាលឡើយ នៅក្នុងក្រុមជំនុំរបស់គាត់ ។ គាត់បានហៅខ្លួនឯងថា ជាអ្នកដឹកនាំក្រុមជំនុំ ។ មានចាស់ទុំ ៤ នាក់

ដែលចែករំលែកកិច្ចការគ្នា ក្នុងការអធិប្បាយប្រចាំអាទិត្យ ។ ការសិក្សាព្រះគម្ពីរ គឺគេយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងក្រុមជំនុំ ។ លោកស្រី ឯម ស៊ីថាន មានសញ្ញាប័ត្រTEE ហើយក្រុមជំនុំក៏មានកម្មសិក្សានៅខាងក្រៅនិងបានបង្រៀនយ៉ាងសកម្មផងដែរ ។ ក្រុមជំនុំ អូឡាំពិក មានសាខានៅ ខេត្តកំពង់ចាម ស្រុកកងមាស បាធាយ និង ស្រុករកាកោង (ខេត្ត កណ្តាល) ។

ចាប់ពីឆ្នាំ ១៩៩៣ រហូតដល់ ១៩៩៧ លោកស្រី ឯម ស៊ីថាន ជាសមាជិកគណៈកម្មាធិការក្រុមបកប្រែគម្ពីរខ្មែរសម្រាយ ជាមួយលោក សុខញឹប អារុណ ។ រហូតមកដល់ខែ មិនា ឆ្នាំ ២០០០ គាត់នៅតែមានតួនាទីពាក់កណ្តាលពេលជាមួយក្រសួងអប់រំ ។ ឥឡូវនេះ គាត់ធ្វើការពេញពេលក្នុងសមាគមព្រះគម្ពីរក្នុងឋានៈជាអគ្គលេខាធិការ។ បេសកកម្មរបស់សមាគមព្រះគម្ពីរ គឺបកប្រែ បោះពុម្ព និង បែងចែកព្រះបន្ទូលរបស់ព្រះទៅមនុស្សគ្រប់រូប នៅគ្រប់ទីកន្លែងទាំងអស់ទូទាំងប្រទេសកម្ពុជា ជាពិសេសសំរាប់ពួកអ្នកមិនជឿ ។

ឯម ស៊ីថាន នៅតែមានសុទិដ្ឋិនិយមចំពោះការរីកផុលផុសនៃជំនឿគ្រីស្ទបរិស័ទនៅក្នុងប្រទេសកម្ពុជា ។ គាត់ឃើញថាក្រុមជំនុំនិងសមាជិកក្រុមជំនុំម្នាក់ៗមានការលូតលាស់ ទាំងផ្នែកវិញ្ញាណ និងទាំងខាងផ្នែកសម្ភារៈ ។ គាត់សូមឲ្យបងប្អូនអ្នកជឿនៅមានជំនឿស្មោះស្ម័គ្រ ចំពោះតែព្រះយេស៊ូ ដែលជាព្រះអង្គសង្គ្រោះតែមួយគត់របស់ពួកគេ ។ គឺមិនត្រូវមានបំណងចង់បានអំណាច ឬចង់បានលាភសក្ការៈ ដោយសារតែជំនឿជាគ្រីស្ទបរិស័ទនោះឡើយ ។ គាត់មានសេចក្តីទុក្ខព្រួយ ដោយឃើញជនជាតិខ្មែរក្រីក្រខំដាក់ទាន និង ចូលលុយកាក់ ដើម្បី កសាងវត្តអារាមដែលកម្រនឹងបានជួយអ្វីដល់សេចក្តីត្រូវការផ្ទាល់ខ្លួន ឬ សេចក្តីត្រូវការផ្នែកវិញ្ញាណរបស់គេនោះឡើយ ។ គាត់មានជំនឿមុតមាំ ចំពោះការដាក់ដង្វាយនៅក្នុងពួកជំនុំ ដង្វាយនោះឯងគេយកទៅប្រើនៅខាង

ក្រៅសំរាប់សេចក្តីត្រូវការនៃការងាររបស់ព្រះជាម្ចាស់ ។ ក្រុមជំនុំ អូឡាំពិក ប្រើប្រាស់ជង្ហាយរបស់ខ្លួនសំរាប់ការងារបេសកកម្ម នៅតាម ខេត្តនានា ។ គាត់រីករាយនឹងចូលរួមប្រកបជាមួយ នឹងគ្រីស្ទបរិស័ទដទៃទៀត ប៉ុន្តែដោយការងារពួកជំនុំ និងការងារសមាគមព្រះគម្ពីរទាមទារ ខ្លាំងពេក ទើបគាត់ខកខានក្នុងការប្រកបខ្លះៗនោះ ។

នៅពេលនិយាយពីការផ្សាយដំណឹងល្អក្នុងប្រទេសកម្ពុជា លោកស្រី ឯម ស៊ីថាន មានគំនិតទូលាយក្នុងការស្វាគមន៍ចំពោះបេសកជនបរទេស ។ គាត់ជឿថាយុទ្ធសាស្ត្រទាំងឡាយ ត្រូវតែស៊ីជាមួយនឹងស្ថានការណ៍នៅក្នុងប្រទេសដែរ ។ ការផ្សាយដំណឹងល្អ គឺត្រូវទៅព្រមជាមួយគ្នាទាំងការផ្សាយជាពាក្យសំដី និង ការផ្សាយតាមបន្ទាល់នៃជីវិតរស់នៅពិត ។ គឺជាការចាំបាច់ណាស់ ដែលយើងត្រូវផ្សាយពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងការដែលយើងត្រូវចេះស្រឡាញ់គ្នាទៅវិញទៅមកដែរ ។ អ្វីដែលគួរធ្វើនោះ គឺមិនត្រូវចំណាយពេលច្រើនជ្រុលហួសដល់ទៅឈ្លោះប្រកែកពីគណៈនិកាយ និង ពីគម្ពីរសម្រាយ និង គម្ពីរបកប្រែចាស់នោះឡើយ ។ អ្វីដែលសំខាន់គឺស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយកោតខ្លាច និង គោរពដល់ព្រះអង្គ ព្រោះមានតែព្រះអង្គប៉ុណ្ណោះ ដែលជាចៅក្រម ។ យើងមិនត្រូវថ្កោលទោសគ្នាឡើយ ។

នៅក្នុងឆ្នាំ ១៩៩៤ មានអ្នកផ្សាយដំណឹងល្អជនជាតិអាមេរិកម្នាក់ឈ្មោះ **ម៉ៃ អេឌិនស៍** បាននាំយកនូវភាពចលាចលនៃ "ការធ្វើការផ្សាយដំណឹងល្អដ៏មានទ្រង់ទ្រាយធំ" មួយមកកាន់កម្ពុជា ។ គាត់បានសន្យាប្រោសជម្ងឺដល់មនុស្សទាំងអស់ ដែលបានមកចូលរួម ហើយក្រោយមកក៏មានការរីករវរ ពីសំណាក់ពួកហ្វូងមនុស្សធ្វើឲ្យឆាកឈរប្រកាសដំណឹងនោះត្រូវរលំរលាយ ។ លោកស្រី ឯម ស៊ីថាន បានឃើញនៅពេល ដែលគេរៀបចំព្រឹត្តិការណ៍នេះឡើង គាត់យល់ឃើញថា គឺគួរឲ្យឆ្ងល់ណាស់ដែលឈ្មោះអ្នកផ្សាយដំណឹងល្អនោះត្រូវបាន គេលើកឲ្យលេចធ្លោខ្ពស់

ជាងព្រះនាមព្រះយេស៊ូគ្រីស្ទទៅទៀត ។ គាត់បានសម្រេចចិត្តថា ក្រុមជំនុំអូឡាំពិកមិនគួរចូលរួមនៅក្នុងព្រឹត្តិការណ៍នេះទេ ។ នៅពេលដែលបុគ្គលិករួមការងារនៅឯក្រសួងអប់រំបាននិយាយចំអកឲ្យគាត់ ចំពោះព្រឹត្តិការណ៍ដែលទទួលបរាជ័យនេះ គាត់គ្រាន់តែឆ្លើយថា "បើអ្នកមានសំណួរអ្វីដែលទាក់ទងនឹងជំនឿគ្រីស្ទបរិស័ទរបស់ខ្ញុំ នោះខ្ញុំរីករាយនឹងនិយាយប្រាប់អ្នកបាន តែផ្ទុយទៅវិញបើអ្នកចង់ឈ្លោះ និងរិះគន់ដល់ព្រឹត្តិការណ៍នោះ ខ្ញុំពិតជាគ្មានអ្វីដែលត្រូវនិយាយទេ" ។ គាត់ជឿថា ក្នុងនាមជាគ្រីស្ទបរិស័ទ នៅពេលដែលបានសិក្សាព្រះបន្ទូលនោះ គេនឹងអាចសំគាល់ព្រមទាំងយល់ដឹងពីព្រះរាជសារ និងអ្នកនាំសារផ្សេងៗដែលបានចូលមកក្នុងប្រទេសកម្ពុជា ។

លោកស្រី ឯម សីថាន ទទួលស្គាល់ថា នៅតែមានផ្តត់គំនិតយល់ខុសជាច្រើន ដែលទាក់ទងទៅនឹងគ្រីស្ទបរិស័ទកម្ពុជា ។ អតីតបុគ្គលិកធ្វើការជាមួយគ្នា នៅក្នុងក្រសួងអប់រំ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានដឹងថា គាត់ជាគ្រីស្ទបរិស័ទ ជាពិសេសគាត់ជាស្ត្រី ដែលមានការអប់រំជ្រៅជ្រះម្នាក់នោះ ។

គាត់បានទទួលនូវការចោទជាសំណួរជាបន្តទៀតថា "តើអ្នកបានទទួលលុយប៉ុន្មាន សំរាប់ការទទួលបើកផ្ទះរបស់អ្នកឯង ធ្វើជាព្រះវិហារនេះ?" គាត់ក៏ឆ្លើយឡើងថា "បើសិនជាអ្នកពិតជាជឿថា ជំនឿរបស់ខ្ញុំ គឺព្រោះតែរឿងលុយ ចុះម៉េចក៏អ្នកមិនបើកផ្ទះរបស់អ្នក ហើយរកលុយឲ្យដូចខ្ញុំទៅ!" ។

លោកស្រី ឯម ស៊ីថាន ជឿជាក់យ៉ាងពិតប្រាកដថា ព្រះជាម្ចាស់មានផែនការសំរាប់គាត់ និង ប្រទេសកម្ពុជា ។ ព្រះអង្គបានបង្ហាញឲ្យគាត់ឃើញនូវសេចក្តីស្មោះស្ម័គ្រ ការគាំពារពេលវេលាដ៏ត្រឹមត្រូវ និងការផ្គត់ផ្គង់របស់ព្រះអង្គ ។ គាត់បានឆ្លើយតបទៅ ព្រះជាម្ចាស់ ដោយមាន

បំណងស្មោះត្រង់បំរើព្រះអង្គ ដោយបន្ទាបខ្លួន ដោយភាពស្មោះត្រង់ និង ដោយក្ដីស្រឡាញ់ដល់ប្រទេសជាតិ និង ប្រជាជាតិរបស់ខ្លួន ។